# ផ្សារសហគមន៍ខ្មែរ

* រហូតដល់សតវត្សទី ២១ សំរាប់ដំណាក់កាលឆ្លងទៅមុខនៃប្រទេសជឿនលឿននិង ប្រទេសកំពុងអភិវឌ្ឍន៍នានា មិនត្រឹមតែបានផ្តល់សុខសន្តិភាពទៅប្រជាពលរដ្ឋរបស់គេប៉ុណ្ណោះទេ ។

ប្រទេសទាំង នេះ ថែមទាំងទុកនូវគំរោងនិងមធ្យោបាយថ្មី សំខាន់ៗ សំរាប់ជម្រុញវិស័យសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ និង ការការពាប្រជាជាតិរបស់គេអោយរីកចំរើនទៅមុខបន្ថែមទៀត ។

Both developed and developing countries have been striving up to the present and will strive steadily into the future not just to bring about peace for their citizenry, but they have prepared and will

continue to prepare major projects and new ways to boost their socioeconomic and political realms and to protect themselves so that they keep progressing forever.

សំរាប់ប្រទេសកម្ពុជា ក៏មិនខុសពីប្រទេសដទៃទៀតដែរ ដោយសារតែកំណើនប្រជាពលរដ្ឋ និង សេចក្តីត្រូវការសំរាប់ជីវភាព ប្រចាំថ្ងៃ ក៏ កាន់កើនឡើង ។ បច្ចុប្បន្នសារធាតុ គីមីបាន និង កំពុងបំផ្លាញជីវិតមនុស្សជារៀងរាល់ ថ្ងៃ ស្មើរ៩០ ភាគរយនៃចំណីអាហារប្រចាំថ្ងៃ ។

កត្តាទាំងនោះហើយ ទើប ក្រុមនិស្សិតស្ម័គ្រចិត្តនៅតាមមហាវិទ្យាល័យមួយចំនួនក្នុងក្រុងភ្នំពេញ ដែលសិក្សារជំនាញ ផ្នែកកសិកម្ម ច្បាប់ អភិវឌ្ឍន៍ជនបទ ធារាសាស្រ្ត កែច្នៃជាដើម ។

As for Cambodia, she is not different from other countries as her population keeps growing
and her needs keep expanding on a daily basis. With the undeniably unchecked development comes the scourge of chemical poisoning that has endangered the daily lives of the people when about 90 percent of the populaces rely on chemicals-tainted foods every day.

កត្តាទាំងនោះហើយ ទើប ក្រុមនិស្សិតស្ម័គ្រចិត្តនៅតាមមហាវិទ្យាល័យមួយចំនួនក្នុងក្រុង ភ្នំពេញ ដែលសិក្សាជំនាញ ផ្នែកកសិកម្ម ច្បាប់ អភិវឌ្ឍន៍ជនបទ ធារាសាស្ត្រ កែច្នៃជាដើម បានចាប់ផ្តើម បង្កើតផ្សារ មួយដែលមានឈ្មោះថា ( ផ្សារសហគមន៍ខ្មែរ ) ដែលមានទីតាំង នៅផ្ទះលេខ 08 ផ្លូវលំ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។

It is because we are well aware of these mind-blowing facts that we--a group of volunteer students from several universities in Phnom Penh with academic expertise in organic farming, law, rural development, irrigation, creative thinking, and so on--have opened a shop known by the name of “Khmer Community Market (KCM)” located at 08 Phlov Lum road in Trea village, Stung Meanchey precinct, Meanchey district, Phnom Penh.

ដើម្បី ទទួលទិញភោគផលរបស់កសិករខ្មែរ នៅតាមបណ្តាខែត្រនានាក្នុងប្រទេសកម្ពុជា ក្នុងនោះដែរ ផ្សារសហគមន៍ខ្មែរ ក៏បានសហការណ៍ជាមួយនិង អង្គការ Greet ដែលអង្គការនេះ មានគម្រោងទៅលើវិស័យកសិកម្ម នៅស្រុកសូ្រត្រនិគម និងស្រុកប្រាសាទបាគង ខែត្រសៀមរាប ។ •



The shop serves as an outlet for small Khmer organic farmers all over the country and also cooperates with GREET, an organization dedicated to promoting organic farming in Cambodia and currently focusing mainly in the neighborhoods of Sotr Nikum and Prasat Bakong districts, Siem Reap province.

ក្នុងគោលបំណងជួយ ដល់ ប្រជាពលរដ្ឋ យល់ដឹងពីគ្រោះថ្នាក់ នៃការប្រើប្រាស់សារធាតុគីមី លើចំណីអាហារ ដើម្បីកាត់ បន្ថយភាពក្រីក្រ ការចំណាកស្រុក ផ្សារសហគមន៍ខ្មែរ បានប្រកាន់គោលជំហរ ដោយ ប្រភពទំនិញជាបេះដូង រីឯទីផ្សារគ្រាន់តែជា កញ្ចក់ឆ្លុះបញ្ចាំងបង្ហាញអោយអតិថិជន ។ បេះដូងរបស់ផ្សារសហគមន៍ ខ្មែរ គឺ បងប្អូន កសិករខ្មែរដែលជឿថា ធម្មជាតិមានសារសំខាន់ជាង ការជឿនលឿន បែបបំផ្លិចបំផ្លាញ អ្វីដែលពួកយើងធ្វើគឺស្រលាញ់ អាណិត និងមេត្តា ។

**With the purposes of essentially assisting the poor rural populaces, educating them about the real dangers from the indiscriminate use of toxic chemicals in food production, and helping to reduce poverty and slow down the exodus of Khmer farmers migrating to neighboring countries in huge numbers, KCM's philosophy is that the sources of goods are the vital part of this business while profits from clients are secondary. KCM's heart is beating thanks to those brotherly Khmer farmers who believe that nature is far more important than destructive progress. What KCM and its vibrant young movers are doing is for the sake of Love, Mercy, and Compassion.**

## ទិសដៅរបស់ផ្សារសហគមន៍ខ្មែរ ៖

## Here are the KCM's objectives:

- គឺជួយ កសិករដែលមិនត្រូវការធ្វើជាទាសករឈ្មួញ ជីគីមី កសិករដែល ស្គាល់ទោសទណ្ឌនៃពួកជីវិទ្យាសាស្រ្ត ស្គាល់ពីតម្លៃកសិកម្មបែប ធម្មជាតិ ដើម្បីអោយមានសុខភាពល្អ ប្រាសចាកជម្ងឺ តម្កាត់ពីការប្រើ ប្រាស់ថ្នាំ គីមី សម្លាប់សត្វល្អិតជាដើម ។
- To help the farmers who do not want to be the slaves of the fertilizer traders, those who understand the nefarious effects of scientific fertilizers and who know the values of natural agriculture, which brings about good health, freedom from diseases and illness due to the use of chemicals and pesticides.




- ដើម្បីជួយពួកគាត់បាន យើងត្រូវមានផ្សារដែលយុត្តិធម៌ចំពោះសេចក្ដីព្យាយាម របស់ពួកគាត់ គឺផ្សារសហគមន៍ខ្មែរ ដែលជាផ្សាររបស់ក្រុមកសិករ ។
- In order to help them, we must have a market that is fair to their efforts, hence KCM, which in essence is a farmers' market.
- ក្នុងនាមយើងជាឈ្មួញកណ្ដាល ដែលមិនរង្វេងនិងការបានប្រាក់កម្រៃពីការគៀបសង្កត់អ្នកផលិត ហើយពួកយើងក៏ធានាចំពោះអតិថិជនផងដែរថាប្រាក់ដែលគេបង់ ដើម្បីទិញទំនិញពីយើងគឺពិតជាមានតម្លៃរបស់វា ។
- In our capacity as the middleman who is not driven by profits from the exploitation of the producers and who guarantees for our clients that the money they spend to purchase goods from us really is worth its face value.

- យើងដឹងហើយថា បច្ចុប្បន្នប្រទេសកម្ពុជាមានទម្លាប់ទិញកសិផលពីបរទេស ដោយអោយតម្លៃផលិតផលបរទេសជាងផលិតផលប្រជាកសិករខ្មែរ បើទោះបីជាបរទេសទាំងនោះយកភោគផលដែលគ្មានគុណភាពនាំអោយគ្រោះថ្នាក់ដល់សុខភាពប្រជាពលរដ្ឋជាពិសេសគឺអនាគតខ្មែរ ។

- We know that Cambodia nowadays has had the habit of purchasing imported farm produce rather than consuming the locally farmed veggies although often times these alien goods are substandard and dangerous to the health of the Khmer citizenry, particularly the youths, the future of Cambodia.

- ពេលនេះគឺជាឪកាសដល់ខ្មែរទូទៅ ដែលអាចបរិភោគ អាហារប្រាសចាកពិស ពុលហើយបន្លែផ្លែឈើដែលទុកចិត្តបានថាគ្មានគីមីពុល គឺកសិផលដែលខ្មែរ ផលិត ដើម្បីខ្មែរ ដូច្នេះខ្មែរត្រូវតែជួយគ្នា ទៅវិញទៅមក ។ ដូច្នេះ អាច និងមានក្រុមខ្លះ ព្យាយាមបង្ខូចឈ្មោះ ផ្សារសហគមន៍ខ្មែរ តាមរយល្បិចកលផ្សេងៗ ប៉ុន្តែផ្សារសហគមន៍ខ្មែរ បានប្រកាន់យកពាក្យ ស្លោកថា ទិញ (**ស្អាត លក់ស្អាត** ) ។
- Now is a chance for Cambodians in general to consume foods without poison and vegetables and fruits that they can trust are free from toxic chemicals. They now have direct access to untainted produce farmed by Khmer for their fellow Khmer. Therefore, we Khmer must help each other. Of course, there are certain groups that have already been trying to vilify KCM through various tricks and methods, but we at KCM have stuck to the “Buy Clean, Sell Clean” slogan.

- សំរាប់ហាងដទៃទៀតប្រើវិធីលក់ដូចយ៉ាងណានោះជាសិទ្ធរបស់ពួកគាត់ ប៉ុន្តែសំរាប់ផ្សារសហគមន៍ខ្មែរ ត្រូវតែស្មោះត្រង់និងសហគមន៍ដែលគេអាច ពឹងពាក់បានថា ជាផ្សាររបស់ខ្លួនផ្ទាល់ គោលដៅរបស់ផ្សារសហគមន៍ ខ្មែរ គឺសំដៅ ស្វែងរកសុខមាលភាពរបស់អ្នកបរិភោគនេះជាគោលដៅ រួមរបស់យើង ។
- As for other shops, whatever methodology they are using is their right but, as far as KCM is concerned, we have pledged to remain loyal to the Khmer communities and honest to our clients who can trust it as their own market. The goal of KCM is to cater to the wellbeing of our clients. This is our common objective.


Khmer Community Shop
Compile a Community Network
Training Agriculture (Vegetable cultivation, processing and livestock) to the community


















# អរគុណ

# Thank you